# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការដំឡើងការិយាល័យអាជីវកម្មរ៉ែ និងថ្មសំភារៈសំណង់ នៃនាយកដ្ឋានធនធានរ៉ែ ទៅជានាយកដ្ឋានរ៉ែសំណង់ ចំណុះអគ្គនាយកដ្ឋានធនធានរ៉ែ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

# រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

# សម្រេច

**មាត្រា១ :** ដំឡើងការិយាល័យអាជីវកម្មរ៉ែ និងថ្មសំភារៈសំណង់ នៃនាយកដ្ឋានធនធានរ៉ែទៅជានាយកដ្ឋានរ៉ែសំណង់ ចំណុះអគ្គនាយកដ្ឋានធនធានរ៉ែ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា២ :** នាយកដ្ឋានរ៉ែសំណង់ មានតួនាទី និងភារកិច្ច ដូចតទៅ :

- រៀបចំគោលការណ៍នានាដែលទាក់ទងដល់ការស្វែងរុករក និងការធ្វើអាជីវកម្មរ៉ែសំណង់ ដែលមានជាអាទិ៍ : ថ្មអារ ថ្មសំណង់ ក្រួស ខ្សាច់សំណង់ ដីឥដ្ឋសំណង់ ឡាតេរីត និងអាចម៍ដី ។

- សិក្សា វិភាគ និងវាយតម្លៃសក្តានុពលធនធានរ៉ែសំណង់ លើផ្នែកបរិមាណ គុណភាព និងសេដ្ឋកិច្ច ។
- ត្រួតពិនិត្យ និងគ្រប់គ្រងការធ្វើអាជីវកម្មធនធានរ៉ែសំណង់ ។
- រៀបចំស្ថិតិផលិតកម្ម-អាជីវកម្មធនធានរ៉ែសំណង់ ។
- គ្រប់គ្រង ត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន ការស្តារបរិស្ថាន និងសុវត្ថិភាពពលកម្ម ។
- សហការ/ពិនិត្យផ្តល់មតិលើផ្នែកបច្ចេកទេសអាជីវកម្ម ឬជីកយក និង វាយតម្លៃរបាយការណ៍បច្ចេកទេសរបស់ក្រុមហ៊ុន/ សម្បទានិក ។
- គ្រប់គ្រង ណែនាំ ពិនិត្យ និងតាមដានការអនុវត្តន៍ច្បាប់ អនុក្រឹត្យ បទប្បញ្ញត្តិ និង បទបញ្ជានានា។
- លើកគំរោង អនុវត្តកិច្ចសហប្រតិបត្តិការជាមួយស្ថាប័ន អង្គការជាតិ និងអន្តរជាតិ ។

**មាត្រា៣ :** នាយកដ្ឋានរ៉ែសំណង់ ដឹកនាំដោយប្រធាន ០១ រូប និង អនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

**មាត្រា៤ :** រចនាសម្ព័ន្ធព្រមទាំងការរៀបចំ និង ការប្រព្រឹត្តទៅរបស់នាយកដ្ឋានរ៉ែសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

**មាត្រា៥ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការដ្ឋានគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីសូមហត្ថលេខា
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

**ស៊ុយ សែម**

**កន្លែងទទួល**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៦
-កាលប្បវត្តិ-ឯកសារ